**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-May-2013, 15:51
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

## សេចក្តីជូនដំណឹងអំពីបំណងដោយអនុលោមតាមវិធាន៩០

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**
សុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
Joshua ROSESWEIG
Forest O'NEILL-GREENBERG
Renee DE GEUS

**ផ្ញើជូន៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**
**លោកស្រី ជា លាង**
**លោក** Andrew CAYLEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
PICH Ang
Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្តីជនជាប់ចោទ នួន ជា (“ក្រុមមេធាវីការពារក្តី”) តទៅនេះសូមដាក់ចម្លើយតបនេះទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យជូនដំណឹងថា តើលោក នួន ជា នឹងឆ្លើយតបចំពោះសំណួរនានាដោយអនុលោមតាមវិធាន៩០ ដែរ ឬយ៉ាងណា៖

១. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង តាមរយៈការណែនាំផ្ទាល់មាត់បានស្នើជនជាប់ចោទនិមួយៗ ផ្តល់ការជូនដំណឹងថា តើពួកគេមានបំណងឆ្លើយតបនឹងសំណួរដោយអនុលោមតាមវិធាន៩០ ដែរ ឬយ៉ាងណា ឬជំនួសមកវិញអនុវត្តសិទ្ធិរបស់ពួកគេនៅស្ងៀមមិនឆ្លើយតបនឹងសំណួរទាំងនោះ។ នៅរសៀលថ្ងៃដដែលនោះ មន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង បានបញ្ជូនសារអេឡិចត្រូនិចទៅកាន់ភាគីទាំងអស់ ដោយបានចង្អុលបង្ហាញថាការជូនដំណឹងបែបនេះ គួរតែធ្វើឡើងជាទម្រង់សារណាលាយលក្ខណ៍អក្សរមិនឲ្យហួសពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ វេលាម៉ោង៩ព្រឹកឡើយ ។

២. នៅវេលាម៉ោង៩ព្រឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីបានបង្ហាញតាមរយៈសារអេឡិចត្រូនិចទៅអង្គជំនុំជម្រះសាលាដំបូងថា នួន ជា នឹង “ឆ្លើយតបសំណួរនានាដែលទាក់ទងនឹងបញ្ហាទាំងឡាយនៅក្នុងវិសាលភាពនៃការជំនុំជម្រះ រហូតដល់ និងរួមបញ្ចូលទាំងការជន្លៀសប្រជាជនដំណាក់កាលទីI និងអង្គហេតុនានាដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ។ គាត់នឹងមិនឆ្លើយនឹងសំណួរទាំងឡាយណាពាក់ព័ន្ធនឹងព្រឹត្តិការណ៍បន្ទាប់ពីនេះដោយរាប់បញ្ចូលរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងនៅបន្ទាប់ពីទួលពោធិ៍ជ្រៃ”។ ក្រុមមេធាវីការពារក្តីបានបង្ហាញបន្ថែមទៀតថា ក្រុមមេធាវីការពារក្តីនឹងដាក់ការបង្ហាញផ្លូវការឲ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន ។ សារអេឡិចត្រូនិចនោះ ត្រូវបានបញ្ជូនទៅភាគីទាំងអស់ ។

៣. អាស្រ័យហេតុនេះក្រុមមេធាវីការពារក្តី សូមដាក់ការជូនដំណឹងនេះ និងបញ្ជាក់ពីបំណងរបស់លោក នួន ជា ដើម្បីឆ្លើយតបទៅនឹងសំណួរនានា ដូចដែលបានចង្អុលបង្ហាញនាពេលកន្លងមក។ លោក នួន ជា នឹងឆ្លើយតបទៅនឹងសំណួរណាមួយ ដែលទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល ទំនាក់ទំនង និង រចនាសម្ព័ន្ធយោធា ក្រោយពីវេលានិយាយខាងលើនៅក្នុងសំណុំរឿងខាងមុខ។

៤. ក្រុមមេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា ដោយសារការអស់កម្លាំងជាបន្តបន្ទាប់ នោះលទ្ធភាពរបស់ នួន ជា ដើម្បីឆ្លើយតបទៅនឹងសំណួរក្នុងរយៈពេលវែង អាចត្រូវបានកម្រិត ។ ចំពោះមូលហេតុនេះ គាត់រក្សាសិទ្ធិទទួលបានការអនុគ្រោះក្នុងការឆ្លើយតបនឹងសំណួរ ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ**

Victor KOPPE